# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

----------

## ក្រុមហ៊ុន កាឡាខេម អ៊ិនវេសមេន ខូអិលធីឌី
## កិច្ចព្រមព្រៀង

រវាង

តំណាងរោងចក្រ ភាគី"ក" ជាមួយ ភាគី"ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ (២០២០) ខែ ឧសភា ថ្ងៃទី ២៧ វេលាម៉ោង១១ និង ០០នាទីថ្ងៃត្រង់នៅការិយាល័យ រោងចក្រ កាឡាខេម អ៊ិនវេសមេន ខូអិលធីឌី មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ភាគី"ក" ជាមួយ ភាគី"ខ" តំណាងប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេល **១ខែ** ចំពោះកម្មករនិយោជិតមួយចំនួន **៧៦** នាក់ មានផ្នែកដេរ ផ្នែកវេចខ្ចប់ ផ្នែកពិនិត្យគុណភាព ផ្នែកជាងម៉ាស៊ីន ផ្នែកឃ្លាំង និងបុគ្គលិកការិយាល័យ ដោយគិតចាប់ពី **ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០** រហូតដល់ **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** ដោយសារអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ១៩ (COVID-19)។

២- ភាគី "ខ" យល់ព្រមទទួល ប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក ពី ភាគី"ក" និង ៤០ ដុល្លារអាមេរិក ដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាល ស្របទៅតាម "សេចក្តីណែនាំរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខៈ **០៤៥/២០ ក.ប/ស.ណ.ន.ខ.ល** ស្តីពី ការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីត-១៩" ដូច្នេះជាសរុបកម្មករនិយោជិតម្នាក់ៗទទួលបាន **៧០ដុល្លារអាមេរិក ក្នុង** ១ខែ សំរាប់រយៈពេលព្យួរការងារនេះ។

៣- ភាគី"ក" នឹងបើក **៣០ ដុល្លារអាមរិក** នេះជូន ភាគី"ខ" នៅថ្ងៃទី១០ នៃខែបន្ទាប់ (តែ១លើកប៉ុណ្ណោះ)។

៤- ភាគី"ខ" ត្រូវត្រលប់ចូលមកធ្វើការវិញនៅថ្ងៃទី **០១ ខែកក្កដា ឆ្នាំ ២០២០** ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ស្តីពីការងារ ។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ០៤ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក២៥៦៣

កំពង់ស្ពឺ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២០

ស្នាមមេដៃតំណាងប្រតិភូបុគ្គលិកកម្មករ និងប្រធានក្រុម

១- ឈ្មោះ ......**ខិន ស្រីមុំ**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..........

២- ឈ្មោះ ......**សួ សារី**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..........

៣- ឈ្មោះ ......**ស៊ុយ អន**...... តួនាទី ......**ប្រតិភូ**...... ហត្ថលេខា ..........

៤- ឈ្មោះ ......**អាំង ហៀង**...... តួនាទី **ប្រធានក្រុម** ហត្ថលេខា ..........

៥- ឈ្មោះ ......**ទូច សុខខេ**...... តួនាទី ......**ប្រតិភូ**...... ហត្ថលេខា ..........

**តំណាងក្រុមហ៊ុន**

**ទេព ណារ៉ុង**

**តួនាទី: រដ្ឋបាល**

ព្រះរាជាណាចក្រកម្ពុជា
កាឡាខេម អ៊ិនវេសមេន
CALACAM INVESTMENT CO.,LTD.
ខេត្តកំពង់ស្ពឺ